# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃព្រហស្បតិ៍ ៨រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៥។

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣៥រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣៣រូប សរុបចំនួន៦៨រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី ការពិនិត្យ និងពិភាក្សាលើ «សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តសេចក្តីសម្រេចចិត្ត កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥» ដោយ **ឯកឧត្តមបណ្ឌិត ស៊ឹម សុផៃ** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានថ្លែងនូវមតិស្វាគមន៍ដល់ក្រុមការងារ និងអង្គប្រជុំ ដោយបានថ្លែងនូវការកោតសរសើរក្រុមការងារក៏ដូចជាក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍កន្លងមក ដែលបង្កឱ្យអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅកម្ពុជា បានធ្លាក់ចុះជាបន្ត។

ជាកិច្ចចាប់ផ្តើម ក្រុមប្រឹក្សាបច្ចេកទេសបានថ្លែងការចូលរួមរំលែកមរណទុក្ខដ៏ក្រៀមក្រំចំពោះប្រជាពលរដ្ឋកម្ពុជាដែលបានបាត់បង់ជីវិតមួយនាក់ និងរងរបួសបីនាក់ ដោយការបាញ់ប្រហារពីសំណាក់

កងទ័ពឈ្លានពានថៃ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ វេលាម៉ោង ១៥:៥០នាទីរសៀល នៅភូមិ ព្រៃចាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

ក្រុមប្រឹក្សាបច្ចេកទេសក៏បានប្រកាសថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះអំពើរំលោភបំពានយ៉ាងគឃ្លើនពីសំណាក់កងទ័ពថៃ ដែលបានបើកការបាញ់ប្រហារមកលើប្រជាពលរដ្ឋខ្មែរ។ ទង្វើអមនុស្សធម៌ដ៏សាហាវឃោរឃៅ យង់ឃ្នងនេះ បង្ហាញយ៉ាងច្បាស់ភាគីថៃបានរំលោភបំពានលើ "សេចក្តីថ្លែងការណ៍រួមស្តីពីកិច្ចព្រមព្រៀងសន្តិភាពរវាងកម្ពុជានិងថៃ" កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា និងថៃ ក្រោមសាក្សីរបស់**ឯកឧត្តម ដូណាល់ ត្រាំ** ប្រធានាធិបតីសហរដ្ឋអាមេរិក និង**ឯកឧត្តម អាន់វ៉ា អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រី ម៉ាឡេស៊ី និងជាប្រធានប្តូរវេនអាស៊ាន។

ឯកឧត្តមបណ្ឌិតអគ្គលេខាធិការប្រធានអង្គប្រជុំ បានថ្លែងនូវការអរគុណ និងកោតសរសើរក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍ ដែលបានប្រឹងប្រែងចូលរួមក្នុងការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍ក្នុងរយៈពេល៦ខែនេះ ដែលទទួលបានសមិទ្ធផលគួជាទីមោទនៈ។ ឯកឧត្តមបណ្ឌិត បានមានប្រសាសន៍ថា កិច្ចប្រជុំលើកទី១១នេះ ក្រុមប្រឹក្សាបច្ចេកទេសនឹងធ្វើការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពស្តីពី ការអនុវត្តសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥ ដែលជាលទ្ធផលនៃការអនុវត្តការងារឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត កាកបាទក្រហម កម្ពុជា និងអង្គការដៃគូ ដែលនឹងត្រូវដាក់ឆ្លងសុំការពិភាក្សា និងឯកភាពក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០២៥ ដែលគ្រោងធ្វើនាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ នៅសាលាប្រជុំអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី។

ក្រោយការធ្វើបទបង្ហាញលើសេចក្តីព្រាងរបាយការណ៍ដោយ **ឯកឧត្តមបណ្ឌិត ស៊ឹម សុផៃ** អគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍រួចមក អង្គប្រជុំបានធ្វើការពិភាក្សា និងផ្តល់យោបល់ទៅលើចំណុចមួយដូចខាងក្រោម៖

- **បច្ចុប្បន្នភាព នៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា**
  - និន្នាការនៃមេរោគអេដស៍លើពិភពលោក ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០២៤
  - និន្នាការនៃមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា
  - ស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅប្រទេសកម្ពុជាមានៈ អ្នកផ្ទុកមេរោគអេដស៍ចំនួន ៧៦ ០០០នាក់ អត្រាប្រេវ៉ាឡង់មាន០,៥%។
  - ស្ថានភាពនៃការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ឆ្នាំ២០២៤ មានអ្នកឆ្លងថ្មីនៃមេរោគអេដស៍ ១២០០នាក់ អ្នកស្លាប់ទាក់ទងនឹងជំងឺអេដស៍ ១០០០នាក់ អ្នកទទួលឱសថ ARV ៦៩ ៩៩៤នាក់។

- **ស្ថានភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០២៥**
  - កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា សម្រាប់ការកសាង និងការពារមាតុភូមិ ឆ្នាំ២០២៣-២០២៨។
  - យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០។
  - ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨។
  - គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ របស់រាជរដ្ឋាភិបាលកម្ពុជា។
  - គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ការឆ្លងថ្មីនៃមេរោគអេដស៍តិចជាង១នាក់/ថ្ងៃ ឬក្នុងរង្វង់ជាង២០០នាក់/ឆ្នាំ ការស្លាប់ដោយសារអេដស៍តិចជាង២០០នាក់/ឆ្នាំ ការរើសអើងនិងការមាក់ងាយអ្នកផ្ទុកមេរោគអេដស៍។
  - សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២៥។
  - លទ្ធផលចម្បងៗនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជា។
  - ពង្រឹងប្រព័ន្ធជាតិឆ្លើយតបជាពហុវិស័យចំពោះមេរោគអេដស៍ និងជំងឺអេដស៍ដែលមានផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៤-២០២៨។
  - ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍ បន្តចូលរួមអនុវត្តគោលនយោបាលជាតិបញ្ចប់អេដស៍។
  - ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីបង្ការ។
  - លទ្ធផលនៃកម្មវិធីគាំពារសង្គម
    - នៅត្រីមាសទី៣ ឆ្នាំ២០២៥ មានអ្នកផ្ទុកមេរោគអេដស៍បានទទួល បណ្ណមូលនិធិសមធម៌ចំនួន ៥០ ៦៧៣នាក់ នៃអ្នកផ្ទុកមេរោគអេដស៍សកម្មកំពុងទទួលART មានចំនួន ៧១ ៧១៦នាក់ គឺស្មើប្រមាណ ៧០,៦% ។
    - គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២៥ ក្រោមការជួយគាំទ្រពីមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន ស្ត្រីធ្វើការក្នុងសេវាកម្សាន្តចំនួន ៧០២នាក់ បានចុះឈ្មោះក្នុងប្រព័ន្ធគាំពារសង្គម (រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ) ក្នុងនោះ ចំនួនស្ត្រី ៤៨៥ នាក់ដែលទទួលបានបណ្ណ ម.ស.ស។
    - មានស្ត្រីធ្វើការក្នុងសេវាកម្សាន្តចំនួន ២១៧នាក់ (ក្រោមការជួយគាំទ្រគម្រោងសុខភាពបន្តពូជ និងសិទ្ធិ (SRHR Program)) កំពង់រង់ចាំកាលបរិច្ឆេទសម្ភាសន៍បណ្ណមូលនិធិសមធម៌ដែលរៀបចំនិងកំណត់ដោយមន្ត្រីទទួលខុសត្រូវ។
- **បញ្ហាប្រឈម**
  - ការឆ្លងមេរោគអេដស៍ថ្មីនៃក្រុមយុវវ័យដែលមានអាយុពី១៥ទៅ២៤ឆ្នាំ មាននិន្នាការកើនឡើង ដោយសារខ្វះការយល់ដឹងអំពីមេរោគអេដស៍ ឬដោយសារការយល់ដឹងនោះមានការថយចុះ។

- ក្រុមប្រជាជនគន្លឹះ ជាពិសេសក្រុមយុវវ័យបុរសរួមភេទជាមួយបុរស(អាយុ១៥-២៤ឆ្នាំ) ជាមុខសញ្ញាងាយរងគ្រោះខ្ពស់ព្រោះពួកគេពុំបានទទួលការបញ្ជ្រាបការយល់ដឹងអំពីហានិភ័យនៃមេរោគអេដស៍និងជំងឺអេដស៍ (Chemsex)។
- ការប្រើប្រាស់ស្រោមអនាម័យបានធ្លាក់ចុះក្រោម៥០ភាគរយ ក្នុងចំណោមក្រុមប្រជាជនគន្លឹះ និងក្រុមយុវវ័យ។
- ការផ្តល់សេវាប្រិ៍ព(PrEP) មិនទាន់សម្រេចគោលដៅដែលបានកំណត់។
- ការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ធ្វើបានតែនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដោយឡែកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ពុំទាន់ដំណើរការបានទាំងស្រុងនៅឡើយ។
- ការអនុវត្តថវិការជួគាំទ្រការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅរដ្ឋបាលខេត្តមួយចំនួនមានការយឺតយ៉ាវ។ ខេត្តមួយចំនួនខ្វះកិច្ចសហការគ្នារវាងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ជាមួយប្រធានគណៈកម្មាធិការប្រយុទ្ធ នឹងជំងឺអេដស៍ និងរដ្ឋបាលខេត្ត។
- ការប្រើប្រាស់កម្មវិធីដែលមានស្រាប់ក្នុងប្រព័ន្ធគាំពារសង្គម ដើម្បីជំរុញការធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនៅមានកម្រិត។
- កង្វះថវិកាសម្រាប់កម្មវិធីអេដស៍ដែលអនុវត្តដោយអង្គការសង្គមស៊ីវិល បានធ្វើឱ្យសកម្មភាពបង្ការការពារធ្លាក់ចុះជាអតិបរមា មិនបានគ្របដណ្តប់គោលដៅងាយរងគ្រោះដូចជា៖ ក្រុមយុវវ័យ បុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ និងក្រុមប្រើប្រាស់ និងចាក់គ្រឿងញៀនឱ្យបានទូលំទូលាយ។
- ការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ធ្វើបានតែនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ដោយឡែកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ពុំទាន់ដំណើរការបានទាំងស្រុងនៅឡើយ។

## ➢ ទិសដៅអនុវត្តបន្ត

- ពង្រឹងនិងពង្រីកការអប់រំផ្សព្វផ្សាយអំពីការយល់ដឹងពីមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានទូលំទូលាយដល់ក្រុម យុវវ័យដែលមានអាយុពី១៥ ទៅ២៤ឆ្នាំ។
- ពង្រឹងនិងពង្រីកការអប់រំផ្សព្វផ្សាយអំពីការយល់ដឹងពីមេរោគអេដស៍ និងជំងឺអេដស៍ឱ្យបានទូលំទូលាយក្រុមប្រជាជនគន្លឹះ ជាពិសេសក្រុមយុវវ័យបុរសរួមភេទជាមួយបុរស(អាយុ១៥-២៤ឆ្នាំ)។
- ជំរុញការអប់រំផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ស្រោមអនាម័យក្នុងចំណោមប្រជាជនគន្លឹះ និងយុវវ័យ។
- ជំរុញការផ្សព្វផ្សាយការយល់ដឹងអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងលក្ខណៈភេទនៅមានកម្រិតក្នុងចំណោមអ្នករៀបចំគោលនយោបាយ អ្នកផ្តល់សេវា និងសហគមន៍។
- ជំរុញការត្រួតពិនិត្យ និងការអនុវត្តច្បាប់នៅតាមកាស៊ីណូ ដើម្បីបង្ការនូវកម្មវិធីបើកបន្ទប់ប្រើគ្រឿងស្រវឹង ប្រើប្រាស់គ្រឿងញៀន និងសេវារួមភេទដោយគ្មានការបង្ការការពារការចម្លងមេរោគអេដស៍។
- ពង្រីកការប្រើប្រាស់កម្មវិធីដែលមានស្រាប់ក្នុងប្រព័ន្ធគាំពារសង្គម ដើម្បីជំរុញការធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត។

- ពិនិត្យលទ្ធភាពបង្កើនថវិកាសម្រាប់កម្មវិធីអេដស៍ដែលអនុវត្តដោយអង្គការសង្គមស៊ីវិល ដើម្បីបង្កើនការគ្របដណ្តប់ក្រុមគោលដៅងាយរងគ្រោះដូចជា៖ ក្រុមយុវវ័យ បុរសរួមភេទជាមួយបុរស ក្រុមបំប្លែងភេទ និងក្រុមប្រើប្រាស់និងចាក់គ្រឿងញៀនឱ្យបានទូលំទូលាយ។
- ពង្រឹង និងពង្រីកការផ្តល់សេវាប្រិព(PrEP) ដើម្បីសម្រេចគោលដៅដែលបានកំណត់។
- ជំរុញការធ្វើសមាហរណកម្មការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ទៅក្នុងប្រព័ន្ធសុខាភិបាលពិសេសការអនុវត្តលិខិតលេខ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានពេញលេញ។
- ពង្រឹងកិច្ចសហការសម្របសម្រួលអ្នកពាក់ព័ន្ធនៅរដ្ឋបាលខេត្ត ដើម្បីជំរុញអនុវត្តថវិការដ្ឋគាំទ្រការប្រយុទ្ធនឹងមេរោគអេដស៍និងជំងឺអេដស៍ ឱ្យមានប្រសិទ្ធភាព និងទាន់ពេល។
- ពង្រឹងភាពជាអ្នកដឹកនាំ ភាពជាម្ចាស់របស់មន្ត្រីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨តាមកាលកំណត់ដោយយកប្រយោជន៍សាធារណៈ និងប្រជាជនជាស្នូលនៃការផ្តល់សេវា។
- បង្កើនថវិកាជាតិពី៣១%នៅឆ្នាំ២០២២ទៅ៥០%នៅឆ្នាំ២០២៨(JMI 2024-2028)។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំផែនការចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាពហុវិស័យ។
- ក្រសួងសុខាភិបាលសម្របសម្រួលការវាយតម្លៃស្ថានភាពសមត្ថភាពរបស់ប្រទេសកម្ពុជា ក្នុងការចុះកិច្ចសន្យាដល់តួអង្គមិនមែនមន្ត្រីរដ្ឋសម្រាប់សេវាបង្ការ និងព្យាបាលមេរោគអេដស៍ ហើយប្រើប្រាស់របកគំហើញនៃការវាយតម្លៃនោះដើម្បីអនុវត្តច្បាប់ គោលនយោបាយ ថវិកា និងអនុសាសន៍ផ្សេងទៀតដែលពាក់ព័ន្ធដូចជាទំនាក់ទំនងជាមួយការគ្របដណ្តប់សុខភាពជាសកល (UHC) និងការថែទាំសុខភាពបឋម(PHC) ដោយយោងលើសំណើរបស់TRP/GFATM។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវពង្រឹងខ្សែបន្ទាត់គណនេយ្យភាពរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីបង្កើនប្រសិទ្ធភាព និងសក្តិសិទ្ធិភាពនៃការប្រើប្រាស់ធនធានឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត ត្រូវពង្រឹងការរៀបចំផែនការរួមឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសម្របសម្រួលការប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍រៀបចំការបណ្តុះបណ្តាលក្នុងការប្រើប្រាស់៖
  - និយាមប្រតិបត្តិស្តង់ដាស្តីពីវិមជ្ឈការនៃការឆ្លើយតបនឹងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិដល់ភាគីពាក់ព័ន្ធ។
  - និយាមប្រតិបត្តិនៃការផ្តល់បណ្ណមូលនិធិសមធម៌សុខាភិបាល (ម.ស.ស.) ដល់បុគ្គលិកបម្រើក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធដល់ភាគីពាក់ព័ន្ធ។

## ៦.មតិយោបល់

- ឯកឧត្តមបានស្នើសុំទៅក្រសួងស្ថាប័នដែលមិនទាន់បានផ្តល់របាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំអេដស៍ សូមផ្តល់របាយការណ៍មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

➢ ក្រសួងសាធារណការ និងដឹកជញ្ជូនស្នើសុំឯកសារ ឬខិតប័ណ្ណនានាដើម្បីផ្សព្វផ្សាយនៅតាមចំណត រថយន្ត កងកម្លាំងប្រដាប់អាវុធ និងកន្លែងសាធារណៈ។

ទន្ទឹមនឹងនោះ **ឯកឧត្តមបណ្ឌិត** បានរំលឹកឡើងវិញនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦ ឆ្នាំ២០២៣-២០២៨ ដែលមានចក្ខុវិស័យៈ ប្រជាពលរដ្ឋកម្ពុជារស់នៅប្រកបដោយសុខភាពល្អ និងមានផលិតភាព មានសិទ្ធិពេញលេញ គ្មានមេរោគអេដស៍ និងជំងឺអេដស៍ និងគ្មានការមាក់ងាយ រើសអើង និងមានបេសកកម្ម ធានាបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្ន ដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន និងមានចីរភាព ដោយមានគោលដៅ ការឆ្លើយតបនឹងមេរោគអេដស៍ជាពហុវិស័យប្រកបដោយចីរភាពដែលធានាថា ជំងឺអេដស៍លែងជាការគំរាមកំហែងសុខភាពសាធារណៈចាប់ពីឆ្នាំ២០២៨។

កិច្ចប្រជុំបានដំណើរការទៅតាមរបៀបវារៈដែលបានគ្រោងទុក និងបញ្ចប់នៅវេលាម៉ោង ១១ព្រឹក ថ្ងៃខែឆ្នាំដដែល ប្រកបដោយលទ្ធផលផ្លែផ្កា។ ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** បានជូនពរដល់សមាជិកអង្គប្រជុំ ឱ្យជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១៣រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| ប្រធានអង្គប្រជុំ | ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន | |
| **បណ្ឌិត ឈឹម យិនដារ៉េត** | **វេជ្ជ. ហួត សេរីរដ្ឋ** | **ស៊ុំ ផល្លា** |